សេចក្តីសង្ខេបភាសាសាមញ្ញនៃគោលនយោបាយជំនួយហិរញ្ញវត្ថុចំពោះការព្យាបាលសុខភាព

ទិដ្ឋភាពទូទៅ

នៅក្នុងដំណើរបេសកកម្មរបស់ខ្លួនដើម្បីលើកកម្ពស់សុខភាពសហគមន៍ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើជនក្រីក្រ និងខ្វះសេវាព្យាបាល Bon Secours Mercy Health ប្តេជ្ញាចិត្តក្នុងការផ្តល់ជំនួយហិរញ្ញវត្ថុដល់អ្នកជំងឺរបស់ខ្លួន។ នេះគឺជាសេចក្តីសង្ខេបនៃគោលនយោបាយជំនួយហិរញ្ញវត្ថុចំពោះការព្យាបាលសុខភាព (HFA) ។

ភាពអាចអនុវត្តបាននៃជំនួយហិរញ្ញវត្ថុ

សិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុត្រូវបានកំណត់ដោយសមត្ថភាពរបស់អ្នកជំងឺ ឬអ្នកតំណាងរបស់គាត់ក្នុងការបង់ប្រាក់ បន្ទាប់ពីធនធានដែលមានទាំងអស់ត្រូវបានប្រើប្រាស់អស់ ហើយកម្មវិធីជំនួយដែលមានទាំងអស់ត្រូវបានវាយតម្លៃរួចរាល់។ ជំនួយហិរញ្ញវត្ថុអាចអនុវត្តបានសម្រាប់ការសង្គ្រោះបន្ទាន់ និងការព្យាបាលចាំបាច់ផ្សេងៗទៀតដែលផ្តល់ដោយមន្ទីរពេទ្យ Bon Secours Mercy Health (និងអ្នកផ្តល់សេវាមួយចំនួនទៀត) ដល់អ្នកជំងឺមិនមានការធានារ៉ាប់រង និងមានការធានារ៉ាប់រង ដែលរស់នៅក្នុងសហគមន៍ នឹងត្រូវបានបម្រើដោយមន្ទីរពេទ្យ Bon Secours Mercy Health ហើយគ្រួសាររបស់ពួកគេមានប្រាក់ចំណូលមិនលើសពីបួនដងនៃគោលការណ៍ណែនាំអំពីភាពក្រីក្ររបស់សហព័ន្ធ (FPG)។

លក្ខខណ្ឌតម្រូវសម្រាប់សិទ្ធិទទួលបាន

ជំនួយហិរញ្ញវត្ថុជាទូទៅត្រូវបានកំណត់ដោយមាត្រដ្ឋានរំកិលនៃប្រាក់ចំណូលគ្រួសារសរុបដែលមានមូលដ្ឋានលើ FPG ។ បុគ្គល ដែលមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុក្រោមគោលនយោបាយរបស់យើង មានកម្រិតប្រាក់ចំណូលនៅ 200% FPG ឬតិចជាងនេះ អាចទទួលការព្យាបាលដោយឥតគិតថ្លៃ។ បុគ្គល ដែលមានកម្រិតប្រាក់ចំណូលពី 201% ទៅ 300% FPG និង 301% ទៅ 400% FPG ទទួលបានការបញ្ចុះតម្លៃម្តងៗខ្លួន ផ្អែកលើមាត្រដ្ឋានរំកិលរួចមានមកនៅក្នុងគោលនយោបាយនេះ។ ការបញ្ចុះតម្លៃភាគរយជាក់លាក់សម្រាប់ 201%-300% FPG និង 301% ទៅ 400% FPG កម្រិតប្រាក់ចំណូលត្រូវបានធ្វើបច្ចុប្បន្នភាពជាម្តងរាល់ឆ្នាំសម្រាប់សមាមាត្រទីផ្សារនីមួយៗស្របតាមការផ្លាស់ប្តូរអតិបរមានុ

មិនមានអរណាម្នាក់ ដែលមានសិទ្ធិទទួលបានជំនួយផ្នែកហិរញ្ញវត្ថុនៅក្រោមគោលនយោបាយ HFA នឹងត្រូវគិតប្រាក់បន្ថែមទៀតសម្រាប់ការសង្គ្រោះបន្ទាន់ ឬការព្យាបាលជួសជុលស្រួលផ្សេងទៀតលើសពីជាងចំនួនទឹកប្រាក់ដែលត្រូវបានទទួលទាត់វិក្កយបត្រជាទូទៅចំពោះបុគ្គលដែលមានធានារ៉ាប់រងលើការព្យាបាលបែបនេះនោះទេ។ ប្រសិនបើមានបុគ្គលណាម្នាក់មានការធានារ៉ាប់រង ឬទ្រព្យសម្បត្តិ គ្រប់គ្រាន់ដើម្បីបង់ប្រាក់សម្រាប់ការព្យាបាលទាំង គាត់ត្រូវបានចាត់ទុកថាមិនមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុឡើយ។ ចំពោះអ្នកជំងឺដែលមិនមានការធានារ៉ាប់រង ហើយមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការបញ្ចុះតម្លៃជំនួយហិរញ្ញវត្ថុណាមួយ ដែលបានពិពណ៌នានៅក្នុងគោលនយោបាយ HFA Bon Secours Mercy Health នឹងបន្ថែមការបញ្ចុះតម្លៃដោយស្វ័យប្រវត្តិ (បង់ដោយខ្លួនឯង) ទៅលើវិក្កយបត្រមន្ទីរពេទ្យរបស់ពួកគេ ។ សូមមើលគោលនយោបាយ HFA ពេញលេញសម្រាប់ការពន្យល់ទាំងស្រុង។

អំពីដំណើរការដាក់ពាក្យស្នើសុំ

ដំណើរការសម្រាប់ការដាក់ពាក្យសុំជំនួយហិរញ្ញវត្ថុក្រោមគោលនយោបាយ HFA របស់យើងរួមបញ្ចូលនូវជំហានទាំងនេះ៖

- បំពេញពាក្យស្នើសុំ HFA និងភ្ជាប់ឯកសារគាំទ្រដែលចាំបាច់។
  - យើងពិនិត្យមើលប្រាក់ចំណូល និងទំហំគ្រួសាររបស់អ្នកដើម្បីកំណត់កម្រិតនៃជំនួយដែលមានសម្រាប់អ្នក។ យើងប្រើមាត្រដ្ឋានរំកិល ដោយផ្អែកលើ FPG បានដែលខាងលើ។
  - យើងតម្រូវឱ្យអ្នក ជាដំបូង ត្រូវតែស្វែងរកសិទ្ធិទទួលបានសម្រាប់ប្រភេទនៃអត្ថប្រយោជន៍សេវាធានារ៉ាប់រងមួយចំនួនដែលអាចគ្របដណ្តប់លើសេវាការព្យាបាលរបស់អ្នក (ឧទាហរណ៍ សំណងកម្មករ សេវាធានារ៉ាប់រងថយន្ត ។ល។) យើងអាចជួយណែនាំអ្នកនូវធនធានសមរម្យមួយចំនួន។
- យើងនឹងទាក់ទងអ្នកដើម្បីប្រាប់ថាតើអ្នកមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុក្រោមគោលនយោបាយ HFA របស់យើងដែរឬទេ។
- យើងអាចជួយអ្នកក្នុងការរៀបចំផែនការទូទាត់ការចំណាយសម្រាប់ការគិតថ្លៃសេវា ឬវិក្កយបត្រផ្សេងៗដែលមិនបានគ្រប់គ្រងគោលនយោបាយ HFA របស់យើង។
  - ផែនការទូទាត់ នឹងពិចារណាលើស្ថានភាពហិរញ្ញវត្ថុរបស់អ្នក ដើម្បីកំណត់លើការទូទាត់ប្រាក់ដែលអ្នកអាចធ្វើទៅបាន។

កន្លែងទទួលព័ត៌មាន

អ្នកអាចទទួលបានច្បាប់ថតចម្លងមួយនៃគោលនយោបាយ HFA របស់យើង និងពាក្យស្នើសុំ HFA ព្រមទាំងព័ត៌មានអំពីដំណើរការស្នើសុំជំនួយហិរញ្ញវត្ថុ (i) ដោយចូលទៅកាន់គេហទំព័ររបស់យើងតាម www.bsmhealth.org/financial-assistance, www.mercy.com/financial-assistance, និង www.fa.bonsecours.com (ii) ដោយការទាក់ទងសេវាហិរញ្ញវត្ថុអ្នកជំងឺ Bon Secours Mercy Health តាមរយៈទូរស័ព្ទលេខ 1-855-732-0138 (iii) ការផ្ញើសំណើសុំទៅកាន់ Mercy Health Public Benefits Dept, PO Box 631774, Cincinnati, OH 45263-1774, ឬ (iv) ដោយការទាក់ទងទៅកាន់អ្នកផ្តល់ប្រឹក្សាហិរញ្ញវត្ថុរបស់យើងដោយផ្ទាល់នៅតាមទីតាំងមន្ទីរពេទ្យរបស់យើង (សូមមើលគោលនយោបាយ HFA ពេញលេញសម្រាប់បញ្ជីទាំងស្រុងនៃទីតាំង និងអាសយដ្ឋាន) ។

យើងជួយជ្រោមជ្រែងប្រជាជនសំខាន់ៗទាំងអស់ដែលទទួលសេវាពី Bon Secours Mercy Health ហើយដែលពួកគាត់មានជំនាញភាសាអង់គ្លេសមានកម្រិត ដោយការបកប្រែឯកសារថតចម្លងនៃគោលនយោបាយ HFA របស់យើង ទម្រង់ពាក្យស្នើសុំ និងសេចក្តីសង្ខេបនេះជាភាសាទម្បូង ដែលប្រជាជនទាំងនោះនិយាយ។ យើងអាចនឹងបោះឆ្នោតជ្រើសរើសដើម្បីផ្តល់ជំនួយបកប្រែ សេចក្តីណែនាំលើការបកប្រែ ឬផ្តល់ជំនួយតាមរយៈការប្រើប្រាស់អ្នកបកប្រែពីភាសាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។